# អ័ប្រាហាំ (ទីមួយ)

## ការប្រកាសព្រះគ្រីស្ទពីគម្ពីរសញ្ញាចាស់ លោកុប្បត្តិ ១២:១-៧

អ្នកនិពន្ធ រ៉ូហ្វ លេភិឡារ

## សេចក្តីណែនាំ

លោកុប្បត្តិ ជំពូក១២ គឺជាជំពូកសំខាន់បំផុតមួយសំរាប់ការយល់អំពីព្រះរាជសារនៅក្នុងព្រះគម្ពីរ។ ប៉ុន្តែគួរអោយសោកស្តាយ នៅពេលមនុស្សអធិប្បាយចេញពីបទគម្ពីរនេះ ជាញឹកញាប់ពួកគេផ្តោតលើការត្រាស់ហៅរបស់អាប់រ៉ាម (អ័ប្រាហាំ) ហើយការអនុវត្តរបស់ពួកគេគឺថា យើងគួរតែស្មោះត្រង់ចំពោះការត្រាស់ហៅរបស់យើង ដូចជាអ័ប្រាហាំបានស្មោះត្រង់ចំពោះការត្រាស់ហៅរបស់គាត់ដែរ។ ជាការពិតហើយដែលអ័ប្រាហាំគឺជាគំរូល្អមួយសំរាប់យើងឲ្យប្រព្រឹត្តតាម ប៉ុន្តែប្រសិនបើយើងយល់ និងអនុវត្តរឿងនេះនៅក្នុងតែរបៀបមួយនេះប៉ុណ្ណោះ នោះយើងពិតជាបានបាត់បង់គំនិតចំបងនៃព្រះរាជសារហើយ។ ដើម្បីអោយយើងយល់បទគម្ពីរនេះកាន់តែច្បាស់ យើងមិនគួរគ្រាន់តែគិតអំពីការត្រាស់ហៅរបស់ព្រះចំពោះអ័ប្រាហាំទេ ប៉ុន្តែក៏គួរតែផ្តោតលើសេចក្តីសន្យារបស់ព្រះជាមួយអ័ប្រាហាំ និងរបៀបដែលសេចក្តីសន្យារបស់ព្រះទាក់ទងជាមួយនឹងអ្វីដែលមានមុននិងអ្វីដែលមានបន្ទាប់មកនៅក្នុងព្រះគម្ពីរផងដែរ។ ការនេះនឹងបញ្ជាក់ច្បាស់លាស់អំពីរបៀបអធិប្បាយព្រះគ្រីស្ទចេញពីលោកុប្បត្តិ ១២ និងរបៀបអនុវត្តបទគម្ពីរនេះសំរាប់គ្រីស្ទបរិស័ទសព្វថ្ងៃ។

## សេចក្តីសន្យារបស់ព្រះជាមួយអាប់រ៉ាម

សេចក្តីសន្យារបស់ព្រះជាមួយអាប់រ៉ាមមានភាពច្បាស់លាស់។ ព្រះជាម្ចាស់នឹង៖
បង្កើតនគរ១យ៉ាងធំពីអាប់រ៉ាម (ខ.២)
ឱ្យពរដល់អាប់រ៉ាម  (ខ.២)
លើកឈ្មោះអាប់រ៉ាមជាធំ (ខ.២)
បញ្ចេញពរដល់មនុស្សទាំងឡាយតាមរយៈអាប់រ៉ាម (ខ.២) គ្រប់ទាំងគ្រួ នៅផែនដីនឹងបានពរដោយសារអាប់រ៉ាម (ខ.៣)
ឱ្យពរដល់អស់អ្នកណា ដែល ឱ្យ ពរដល់អាប់រ៉ាម ហើយនឹង ដាក់បណ្តាសាដល់អស់អ្នកណា ដែលផ្តាសាគាត់ (ខ.៣)
ឱ្យស្រុកកាណានដល់ពូជអាប់រ៉ាម (ខ.៧)

## តើ សេចក្តីសន្យាទាំងនេះភ្ជាប់ទាក់ទងនឹងបទគម្ពីរមុន (លោកុប្បត្តិ ១-១១) យ៉ាងដូចម្តេច?

ជាការសំខាន់ចាំបាច់ក្នុងការយល់អំពីគោលដៅរបស់ព្រះជាម្ចាស់ក្នុងការបង្កើតអ្វីៗសព្វសារពើ។ គោលដៅរបស់ទ្រង់គឺថា យើងទាំងអស់គ្នានឹងរីករាយជាមួយសេចក្តីសំរាករបស់ព្រះ (សូមមើលមេរៀនអំពីការអធិប្បាយព្រះគ្រីស្ទចេញពីលោកុប្បត្តិ ២:១-៣ ថ្ងៃទីប្រាំពីរ) គឺរាស្ត្ររបស់ព្រះ (ដំបូងមានអ័ដាមនិងអេវ៉ា) នឹងមាននៅក្នុងទីកន្លែងរបស់ទ្រង់ ក្រោមការគ្រប់គ្រងនិងព្រះពររបស់ទ្រង់។ យើងបានបាត់បង់សេចក្តីសំរាកនេះ នៅពេលអ័ដាមនិងអេវ៉ាបានបះបោរប្រឆាំងនឹងព្រះ។ ចាប់តាំងពីការបះបោរប្រឆាំងរបស់អ័ដាមនិងអេវ៉ាមក មនុស្សជាតិបាននៅក្រោមបណ្តាសា ប៉ុន្តែព្រះចង់ប្រទានព្រះពរដល់មនុស្សជាតិ។ អ័ដាមនិងអេវ៉ាត្រូវបានព្រះបណ្តេញចេញពីសួនច្បារ ដែលជាទីបរិសុទ្ធរបស់ព្រះ។ ផែនការណ៍របស់ព្រះ ដែលបានបើកសំដែងពេញក្នុងព្រះគម្ពីរ គឺដើម្បីដោះស្រាយបញ្ហានេះ ហើយសំរេចគោលដៅរបស់ទ្រង់សំរាប់ស្នាព្រះហស្ត។ សំនួរធំមួយសួរថា «តើព្រះនឹងធ្វើការនេះដោយរបៀបណា?» គឺតាមរយៈសេចក្តីសន្យាទាំងនេះដែលព្រះមានជាមួយអ័ប្រាហាំហើយ ដែលទ្រង់នឹងដោះស្រាយបញ្ហា ដែលបានចេញមកពីអ័ដាមនិងអេវ៉ា ហើយប្រទានពរដល់លោកិយ។ សេចក្តីសន្យាផ្សេងៗរបស់ព្រះជាមួយអ័ប្រាហាំទាក់ទងជាមួយគោលដៅដំបូងរបស់ព្រះសំរាប់ស្នាព្រះហស្ត ដូចជាយើងមើលឃើញនៅក្នុងតារាងខាងក្រោមនេះ។

| | លោកុប្បត្តិ ២ | សេចក្ដីសន្យាចំពោះអ័ប្រាហាំ (លោកុប្បត្តិ ១២) |
|---|---|---|
| **រាស្ត្ររបស់ព្រះ** | អ័ដាម និងអេវ៉ា | អ័ប្រាហាំ និងពូជពង្សរបស់គាត់ |
| **ទីកន្លែងរបស់ព្រះ** | សួនច្បារអេដែន | ទឹកដីសន្យា (១២:៧) |
| **ការគ្រប់គ្រង និងព្រះពររបស់ព្រះ** | មានព្រះបន្ទូលនិងពររបស់ទ្រង់ | ទទួលព្រះពរ និងធ្វើជាព្រះពរ (១២:២-៣) |

## សេចក្ដីលំអិតអំពីផ្ទៃរឿងទាំងនេះ៖

ទឹកដី ព្រះពរ និងបណ្ដាសា៖ អ័ប្រាហាំគឺដូចជាអ័ដាមថ្មីម្នាក់។ ព្រះប្រទានសួនច្បារអេដែនដល់អ័ដាម ហើយទ្រង់ប្រទានទឹកដីកាណានដល់អ័ប្រាហាំ ដែលដូចជាអេដែនថ្មីមួយ (១៣:១០)។

ផ្ទៃរឿងអំពីទឹកដី ព្រះពរ និងបណ្ដាសារួមបញ្ចូលគ្នា នៅពេលយើងមើលឃើញនរណាបានរស់នៅក្នុងទឹកដី និងសកម្មភាពរបស់ព្រះ។ នៅពេលអ័ប្រាហាំបានមកដល់ ពេលនោះសាសន៍កាណានបានរស់នៅក្នុងទឹកដី (ខ. ៦)។ ពួកគេត្រូវបណ្ដាសាដោយណូអេ (លោកុប្បត្តិ ៩:២៥) ហើយជាពូជនៃសត្វពស់។ អ័ប្រាហាំបានធ្វើដំណើរកាត់តាមទឹកដី ស្អាងអាសនាថ្វាយព្រះដ៏ពិតនៅកន្លែងយុទ្ធសាស្ត្រ ដែលជិតអាសនាសំរាប់រូបព្រះរបស់សាសន៍កាណាន។ អ័ប្រាហាំបានប្រកាសថា ទឹកដីនេះគឺសំរាប់ព្រះ ហើយឧទ្ទិសទឹកដីសន្យាដល់ព្រះ ដូច្នេះផ្លាស់ប្ដូរទឹកដីនេះពីទឹកដីរបស់អ្នកត្រូវបណ្ដាសា (សាសន៍កាណាន) ទៅជាទឹកដីរបស់អ្នកមានពរវិញ ដូចជាណូអេបានឧទ្ទិសផែនដីដែលសំអាតដោយទឹកជំនន់ថ្វាយដល់ព្រះដែរ (៨:២០)។

ឈ្មោះ៖ ក៏មានទំនាក់ទំនងជាមួយលោកុប្បត្តិ ១១ផងដែរ។ មនុស្សនៅក្រុងបាបិលបានព្យាយាមធ្វើអោយឈ្មោះរបស់ពួកគេបានជាធំ ប៉ុន្តែព្រះសន្យាជាមួយអ័ប្រាហាំថា ព្រះនឹងធ្វើអោយឈ្មោះរបស់គាត់បានជាធំ។

## តើសេចក្ដីសន្យាទាំងនេះជាប់ទាក់ទងនឹងបទគម្ពីរក្រោយ (លោកុប្បត្តិ ១២-វិវរណៈ) យ៉ាងដូចម្ដេច?

ផ្នែកទាំងអស់ទៀតនៃព្រះគម្ពីរគឺនិយាយអំពីព្រះបំពេញសំរេចផែនការណ៍របស់ទ្រង់ ដើម្បីស្ដាគោលបំណងល្អរបស់ទ្រង់នៅក្នុងការបង្កបង្កើត ដោយបំពេញសំរេចសេចក្ដីសន្យាទាំងនេះជាមួយអ័ប្រាហាំ។ ជាឧទាហរណ៍ ផ្នែកទាំងអស់ទៀតនៃកណ្ឌលោកុប្បត្តិនិយាយអំពីអ្នកទទួលបានសេចក្ដីសន្យាទាំងនេះ (អ៊ីសាក បន្ទាប់មកយ៉ាកុប និងពូជពង្សរបស់គាត់)។ នៅពេលអ៊ីស្រាអែលបានចូលក្នុងទឹកដីនៅក្នុងកណ្ឌយ៉ូស្វេ ពួកគេកំពុងចូលទៅក្នុងទឹកដី ដែលព្រះបានសន្យាជាមួយពួកគេ តាមរយៈអ័ប្រាហាំ ហើយអ័ប្រាហាំបានឧទ្ទិសថ្វាយដល់ព្រះ តាមរយៈការស្អាងអាសនារបស់ព្រះ។

សំនួរសំខាន់មួយសួរថា «តើមនុស្សទាំងអស់នៅលើផែនដីទទួលបានព្រះពរតាមរយៈអ័ប្រាហាំយ៉ាងដូចម្ដេច?» (១២:៣)។ «មនុស្សទាំងអស់» រួមទាំងជនជាតិខ្មែរផងដែរ អញ្ចឹង តើជនជាតិខ្មែរទទួលបានព្រះពរតាមរយៈអ័ប្រាហាំយ៉ាងដូចម្ដេច?

ទីមួយ សេចក្ដីសន្យាទាំងនេះគឺជាមូលដ្ឋានគ្រឹះសំរាប់ការបង្កើតជាតិសាសន៍អ៊ីស្រាអែល (ទាំងមនុស្ស និងទឹកដី) ហើយព្រះបានហៅពួកគេអោយធ្វើជាទីបញ្ចេញព្រះពរដល់លោកិយ ដោយបានប្រទានអោយពួកគេនូវព្រះបន្ទូលរបស់ទ្រង់ ដែលបានបើកសំដែងអំពីអង្គទ្រង់ និងផ្លូវរបស់ទ្រង់ ហើយពួកគេត្រូវតែទុកចិត្ត និងស្ដាប់បង្គាប់តាមព្រះបន្ទូលនោះ (និក្ខមនំ ១៩:៤-៦; ចោទិយកថា ៤:៥-៨) ហើយប្រាប់ជាតិសាសន៍ដទៃអំពីព្រះ (ទំនុកដំកើង ១០៥:១)។ ប្រសិនបើពួកគេបានធ្វើការនេះ នោះពួកគេគឺជាពន្លឺ និងព្រះពរដល់លោកិយហើយ ប៉ុន្តែអ៊ីស្រាអែលបានបរាជ័យបំពេញតួនាទីនេះ។

ចុងបំផុត ព្រះយេស៊ូវ ដែលជាពូជពង្សរបស់អ័ប្រាហាំ បានយាងមកក្នុងលោកិយ ជាពន្លឺនៃលោកិយ ដើម្បីសង្គ្រោះយើងឲ្យចេញពីអំពើបាបរបស់យើង។ គឺតាមរយៈការយាងមករបស់ព្រះយេស៊ូវ ដើម្បីសង្គ្រោះពួកយូដានិងសាសន៍ដទៃឲ្យចេញពីអំពើបាបរបស់ពួកគេហើយដែល *គ្រប់ទាំងគ្រួនៅផែនដីនឹងបានពរដោយសារ*អាប់រ៉ាម។

នេះគឺជារបៀបដែលអ្នកនិពន្ធក្នុងព្រះគម្ពីរសញ្ញាថ្មីកាត់ស្រាយ និងអនុវត្តសេចក្តីសន្យារបស់ព្រះជាមួយអ័ប្រាហាំ។ ជាឧទាហរណ៍ នៅក្នុងកាឡាទី ៣:៦-១៨ ប៉ុលបង្រៀនថា ព្រះពរដែលព្រះបានសន្យាប្រទានដល់លោកិយ តាមរយៈអ័ប្រាហាំគឺថា ព្រះសង្គ្រោះយើងឲ្យចេញពីអំពើបាបរបស់យើង (រាប់យើងជាសុចរិត ហើយប្រទានព្រះវិញ្ញាណបរិសុទ្ធដល់យើង) ហើយថា យើងទទួលបានព្រះពរនេះដោយសេចក្តីជំនឿលើព្រះគ្រីស្ទ។ ដូច្នេះ នេះមានន័យថា ប្រសិនបើយើងយល់ និងអនុវត្តលោកុប្បត្តិ ១២ បានត្រឹមត្រូវ នោះយើងត្រូវតែអធិប្បាយដំណឹងល្អរបស់ព្រះគ្រីស្ទ។ យើងមិនទទួលបានព្រះពរ ដែលព្រះបានសន្យាជាមួយអ័ប្រាហាំ តាមរយៈភាពស្មោះត្រង់ផ្ទាល់ខ្លួនរបស់យើងទេ ប៉ុន្តែយើងទទួលបានដោយការទុកចិត្តដល់ព្រះគ្រីស្ទវិញ។ ប្រសិនបើយើងពឹងផ្អែកលើការស្តាប់បង្គាប់របស់យើង នោះយើងស្ថិតនៅក្រោមបណ្តាសាហើយ (កាឡាទី ៣:១០)។

លើសពីនេះ គឺតាមរយៈព្រះគ្រីស្ទដែលយើងឥឡូវនេះក្លាយជារាស្ត្ររបស់ព្រះ។ ដូច្នេះ តាមរយៈព្រះគ្រីស្ទដែលព្រះកំពុងបំពេញសំរេចគោលបំណងរបស់ទ្រង់ក្នុងការបង្កបង្កើត ដើម្បីមានមនុស្សមួយក្រុមដែលជារបស់ទ្រង់។ គឺតាមរយៈព្រះគ្រីស្ទដែលយើងចូលទៅក្នុងទីកន្លែងចុងក្រោយរបស់ព្រះ។ ដូច្នេះ សេចក្តីសន្យារបស់ព្រះជាមួយអ័ប្រាហាំគឺជាគន្លឹះដើម្បីយល់អំពីរបៀបដែលព្រះគម្ពីរទាំងមូលស៊ីគ្នាជារឿងតែមួយ ដែលមានព្រះគ្រីស្ទជាចំនុចស្នូល ហើយគឺតាមរយៈព្រះគ្រីស្ទដែលរឿងអំពីអ័ប្រាហាំមានការអនុវត្តចំពោះយើង។

## អ័ប្រាហាំ និងព្រះគ្រីស្ទ

ការប្រៀបធៀបអ័ប្រាហាំជាមួយព្រះគ្រីស្ទផ្តល់របៀបមួយនៃការអធិប្បាយអំពីព្រះគ្រីស្ទ។ ឧទាហរណ៍ អ័ប្រាហាំដែលជាពូជស្ត្រី (លោកុប្បត្តិ ៣:១៥) បានស្តាការថ្វាយបង្គំព្រះពិតនៅក្នុងទឹកដីកាណានឡើងវិញ ដូចជាព្រះយេស៊ូវដែលជាពូជចុងក្រោយរបស់ស្ត្រីដើម្បីកិនក្បាលរបស់សត្វពស់ និងជាពូជរបស់អ័ប្រាហាំ បានយាងមកស្តាការថ្វាយបង្គំព្រះពិត ហើយបញ្ជូនយើងចេញទៅលោកិយទាំងមូល ដើម្បីបង្កើតសិស្សពេញទាំងលោកិយ និងប្រកាសឡើងវិញថាលោកិយជារបស់ព្រះ ហើយនាំអោយមានការថ្វាយបង្គំដ៏ពិតនៅក្នុងលោកិយទាំងមូល។ ដូចដែលព្រះបានប្រទានអោយអ័ប្រាហាំមានឈ្មោះជាធំ នោះព្រះដ៏ជាព្រះវរបិតាក៏បានប្រទាននាមដ៏ធំបំផុតដល់ព្រះយេស៊ូវផងដែរ (ភីលីព ២:៩)។

នៅពេលអធិប្បាយ បញ្ហាមួយសំរាប់អ្នកអធិប្បាយគឺថា បទគម្ពីរនេះមានផ្ទៃរឿងច្រើនពេក ធ្វើអោយសេចក្តីអធិប្បាយរបស់យើងមានផ្ទៃរឿងច្រើនពេកដែរ។ សេចក្តីអធិប្បាយមួយមិនចាំបាច់មានគំនិតទាំងអស់ខាងលើទេ ប៉ុន្តែអាចផ្តោតលើផ្ទៃរឿងមួយ ឧទាហរណ៍ដូចជា ព្រះពរ និងបណ្តាសា។ បើអញ្ចឹង គំនិតចំបងអាចជា «យើងទទួលបានព្រះពរ ដែលព្រះបានសន្យាជាមួយអ័ប្រាហាំ ដោយការទុកចិត្តព្រះគ្រីស្ទ» (កាឡាទី ៣:៦-១១)។